**ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២៦ ខែ មិនា ឆ្នាំ២០១៤

## ជប៉ុនផ្តល់ ៤៥៥,៨៧៨ ដុល្លារអាមេរិក សម្រាប់គម្រោងចំនួនបួន

ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុនជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ(ជំនួយគូសាណូណិ) រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន៤៥៥,៨៧៨ ដុល្លាអាមេរិកដល់ស្ថាប័នទទួលជំនួយចំនួន៤។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយឯកឧត្តម គូម៉ាម៉ារ៉ូយូជិ ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជានិងតំណាងស្ថាប័នទទួលជំនួយទាំង៤សម្រាប់គម្រោងដូចតទៅ៖

<ins>១. គម្រោងកែលម្អបរិស្ថានអប់រំនៅសាលាបឋមសិក្សានិងអនុវិទ្យាល័យច្រកត្នោត ខេត្តកំពង់ឆ្នាំង (១០៨,៧៩៣ដុល្លាអាមេរិក)</ins>



<ins>ស្ថាប័នទទួលជំនួយ៖ អង្គការជីវិតថ្លៃថ្នូរ</ins>

គម្រោងនេះគឺដើម្បីសាងសង់អគារសិក្សា និងបំពាក់គ្រឿងសង្ហារឹមក្នុងសាលាបឋមសិក្សា និងអនុវិទ្យាល័យច្រកត្នោតក្នុងខេត្តកំពង់ឆ្នាំង។ ជាមួយនឹងគម្រោងនេះ យើងសង្ឃឹមថា សិស្សានុសិស្សប្រមាណជាង ៥០០នាក់ នៃសាលាបឋមសិក្សា និងអនុវិទ្យាល័យច្រកត្នោតនឹងរីករាយជាមួយការសិក្សាក្នុងបរិស្ថានអប់រំដែលត្រូវបានកែលម្អនេះ។



<ins>២. គម្រោងសាងសង់អគារសិក្សានៅអនុវិទ្យាល័យព្រែកកំពឹស រាជធានីភ្នំពេញ (១០៧,៦០០ដុល្លាអាមេរិក)</ins>

<ins>ស្ថាប័នទទួលជំនួយ៖ មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ</ins>

គម្រោងនេះគឺដើម្បីសាងសង់អគារសិក្សាមួយខ្នងនៅអនុវិទ្យាល័យព្រែកកំពឹស រាជធានីភ្នំពេញ។ តាមរយៈគម្រោងនេះសិស្សានុសិស្សប្រមាណជាង៤០០នាក់នឹងអាចសិក្សាក្នុងថ្នាក់រៀនដែលមានសុវត្ថិភាព និងប្រកបដោយផាសុខភាព។

<ins>៣. គម្រោងសាងសង់អគារសាលាមត្តេយ្យចំនួន៣ក្នុងស្រុកកោះធំ និងស្រុកអង្គស្នួល ខេត្តកណ្តាល (១១៨,៧៥៩ដុល្លាអាមេរិក)</ins>



<ins>ស្ថាប័នទទួលជំនួយ៖ សមាគមគ្រួសារយើង</ins>

គម្រោងនេះគឺដើម្បីសាងសង់អគារសាលាមត្តេយ្យចំនួន៣ខ្នងដោយមានបំពាក់សង្ហារឹម និងបរិក្ខារអនាម័យនៅសាលាមត្តេយ្យពងទឹកក្នុងស្រុកអង្គស្នួល និងសាលាមត្តេយ្យក្បាលកោះទាវ និងសាលាមត្តេយ្យកំពង់ថ្កុលក្នុងស្រុកកោះធំ ខេត្តកណ្តាល។ តាមរយៈគម្រោងនេះ សិស្សមត្តេយ្យប្រមាណជាង២៣០នាក់នឹងរីករាយជាមួយការសិក្សាក្នុងថ្នាក់រៀនដែលមានសុវត្ថិភាព និងប្រកបដោយ



ផាសុខភាព។

<u>៤. គម្រោងសាងសង់អគារពហុប្រយោជន៍ជាមួយសាលវិទ្យាសាស្ត្រនៅសាលាគរុកោសល្យ និងវិក្រឹតការខេត្តក្រចេះ (១២០,៧២៦ដុល្លាអាមេរិក)</u>

<u>ស្ថាប័នទទួលជំនួយ៖ សាលាគរុកោសល្យ និងវិក្រឹតការខេត្តក្រចេះ</u>

គម្រោងនេះ គឺដើម្បី សាងសង់អគារពហុប្រយោជន៍មួយខ្នង ដែលរួមមានសាលវិទ្យាសាស្ត្រមួយ និងបំពាក់សង្ហារឹម និងបរិក្ខារអនាម័យនៅសាលាគរុកោសល្យ និងវិក្រឹតការខេត្តក្រចេះ។ តាមរយៈគម្រោងនេះ គរុសិស្សប្រមាណ ១២០នាក់ ដែលនឹងក្លាយជាគ្រូបឋមសិក្សា នឹងទទួលបានអត្ថប្រយោជន៍ដោយផ្ទាល់ពីការកែលម្អបរិស្ថានអប់រំនេះ។

ជំនួយ *គូសាណូណេ* របស់ រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍និងស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជិវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជុំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង ៥១.៨ លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន ៥១៧ គម្រោងនៅទូទាំង



ប្រទេស។

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*
*អ៊ីមែល: eco.jpn@.pp.mofa.go.jp*
*គេហទំព័រ: http://www.kh.emb-japan.go.jp*